# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Aug-2014, 13:52
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៤

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ចម្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន និង នួន ជា សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងករណី០០២/០១

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តី នួន ជា៖**

សុន អរុណ

Victor KOPPE

**ក្រុមមេធាវីការពារក្តី ខៀវ សំផន៖**

KONG Sam Onn
Anta GUISSÉ
Arthur VERCKEN

**ចម្លងជូន៖**

**សហចៅក្រមជាន់ខ្ពស់** 

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

សហមេធាវី នួន ជា និង សហមេធាវី ខៀវ សំផន ("ក្រុមមេធាវីការពារក្តី") តទៅនេះសូមដាក់ចម្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន សុំពន្យារពេល និងបង្កើនចំនួនទំព័រទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១។

១. នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានដាក់រួមគ្នាសំណើសុំបន្ថែមចំនួនទំព័រ និងសុំពន្យារពេលវេលាកំណត់សម្រាប់ទាំងសេចក្តីជូនដំណឹងអំពីបណ្តឹងសារទុក្ខ និងសារណាបណ្តឹងសាទុក្ខទាក់ទងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ("សំណើសុំបង្កើនចំនួនទំព័រ និងសុំពន្យារពេលកំណត់"[1]។ សំណើនេះស្នើសុំការបង្កើនចំនួនទំព័រសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខពី៣០ទំព័រ ទៅ៥០ទំព័រជាភាសាអង់គ្លេស ឬភាសាបារាំង, បង្កើនចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខពី៣០ទំព័រ ទៅ១៥០ទំព័រ ជាភាសារអង់គ្លេស ឬភាសាបារាំង, ពន្យារពេលកំណត់សម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខពី៣០ថ្ងៃ ទៅ៦០ថ្ងៃ បូកនឹងការបន្ថែមពេល១៤ថ្ងៃសម្រាប់ការបកប្រែ និងការពន្យារពេលកំណត់សម្រាប់ការដាក់បណ្តឹងសាទុក្ខពី៦០ថ្ងៃ ទៅ ៧៥ថ្ងៃ បូកនឹងការបន្ថែមពេល៤២ថ្ងៃសម្រាប់ការបកប្រែ[2]។ នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតប ("ចម្លើយតប")[3]។ សហព្រះរាជអាជ្ញាមិនបានជំទាស់ទៅនឹងចំនួនទំព័រដែលបានស្នើនោះទេ ឲ្យតែការបង្កើនចំនួនទំព័រព្រមគ្នាសម្រាប់សារណាឆ្លើយតបរបស់ខ្លួនមានចំនួនត្រឹម៣០០ទំព័រ ដែលជាចំនួនទំព័ររួមគ្នានៃសារណាបណ្តឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្តីទាំងពីរ។ សហព្រះរាជអាជ្ញាបានជំទាស់សំណើសុំ ពន្យារពេលកំណត់សម្រាប់ការដាក់សេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខ ហើយបានស្នើឲ្យផ្តល់ការពន្យារបន្ថែមតែចំនួន៣០ថ្ងៃ សម្រាប់ការដាក់

---

[1] ឯកសារ F3 "សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន និងមេធាវីការពារក្តី លោក នួនជា សុំពន្យាពេលកំណត់ និងបង្កើនចំនួនទំព័រនៃបណ្តឹងសាទុក្ខ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០១៤ ("សំណើសុំបង្កើនចំនួនទំព័រ និងសុំពន្យារពេលកំណត់")។

[2] សំណើសុំបង្កើនចំនួនទំព័រ និងសុំពន្យារពេលកំណត់ នៅកថាខណ្ឌ៣១។

[3] ឯកសារ F3/1 "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ក្រុមមេធាវីការពារ ខៀវ សំផន និង នួន ជា សុំពន្យាពេលកំណត់ និងបង្កើនចំនួនទំព័រទាក់ទងនឹងបណ្តឹងសារទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងករណី០០២/០១ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ ("ចម្លើយតប")។

សារណាបណ្តឹងសាទុក្ខ ជាលទ្ធផលគឺ៩០ថ្ងៃចាប់តាំងពីការដាក់ការជូនដំណឹងអំពីបណ្តឹងសាទុក្ខ។ សហព្រះរាជអាជ្ញាបានស្នើរយៈពេល៩០ថ្ងៃដែរ គឺចាប់ពីថ្ងៃដាក់បណ្តឹងសាទុក្ខ ដើម្បីដាក់ការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខ[4]។ អនុលោមតាមមាត្រា ៨.៤ នៃសេចក្តីណែនាំស្តីពីការអនុវត្តការ ដាក់ឯកសារ តទៅនេះក្រុមមេធាវីការពារក្តីសូមដាក់ចម្លើយតបនេះទៅនឹងសារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញា[5]។

## ក. ចំនួនទំព័រកំណត់សម្រាប់សហព្រះរាជអាជ្ញា

២. សហព្រះរាជអាជ្ញាមិនគាំទ្រសំណើរបស់ខ្លួន ដើម្បីដាក់ចម្លើយតបរួម ដែលមានចំនួនស្មើគ្នានឹងចំនួនទំព័រនៃសារណាបណ្តឹងសាទុក្ខរួមរបស់ក្រុមមេធាវីការពារក្តី ដោយយោងទៅយុត្តិសាស្ត្រច្បាប់ណាមួយនោះទេ។ អនុលោមតាមការអនុវត្តនៅកម្រិតអន្តរជាតិ ចំនួនទំព័រសម្រាប់ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងពហុសារណានៃបណ្តឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្តី ត្រូវបានអនុញ្ញាតឲ្យបង្កើនចំនួនទំព័រសមរម្យចំពោះសារណាបណ្តឹងសាទុក្ខនិមួយៗ។ សេចក្តីណែនាំអនុវត្តពីការដាក់ឯកសារនៅតុលាការ ICTR និង ICTY ចំនួនទំព័រនៃបណ្តឹងសាទុក្ខ និងញត្តិបណ្តឹងសាទុក្ខ ត្រូវបានផ្តល់ចំនួន ៣០ ០០០ ពាក្យជាអតិបរមាណ សម្រាប់បណ្តឹងសាទុក្ខណាមួយរបស់ក្រុមមេធាវីការពារក្តី ហើយចំនួនទំព័រគោលសម្រាប់សារណាថ្លើយតបរបស់ព្រះរាជអាជ្ញា គឺ ៣០ ០០០ ពាក្យចំពោះជនជាប់ចោទម្នាក់ ហើយបន្ថែម ១០ ០០០ ពាក្យសម្រាប់ជនជាប់ចោទនិមួយៗ[6]។ ប្រសិនអង្គជំនុំជម្រះអនុញ្ញាតសំណើរបស់ក្រុមមេធាវីការពារក្តីសុំចំនួន១៥០ទំព័រសម្រាប់ជនជាប់ចោទនិមួយៗ នោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាក៏ត្រូវកំណត់ត្រឹមតែ២០០ទំព័រដែរ។ ការកំណត់ចំនួនទំព័រនេះគិតទៅដល់ការត្រួតគ្នានៅក្នុងបញ្ហាសារធាតុជាច្រើនដែលទំនងនឹងកើតឡើងនៅក្នុងសារណាបណ្តឹង

---

[4] ចម្លើយតបនៅកថាខណ្ឌ៧។

[5] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អវតក, សេចក្តីណែនាំអនុវត្ត អវតក/០១/០០៧/វិសោធនកម្មលើកទី៧ (“សេចក្តីណែនាំអនុវត្តការដាក់ឯកសារ”) មាត្រា ៨.៤ (អនុញ្ញាតឲ្យឆ្លើយតបក្នុងរយៈពេល៥ថ្ងៃនៃប្រតិទិន នៅក្នុងករណីមិនមានការស្នើសុំឲ្យមានការដេញដោលផ្ទាល់មាត់)។

[6] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ ICTR និង ICTY ចំណុច C(1)(a),(b) ។ សូមមើលផងដែររឿងក្តី Mugenzi និង Mugiraneza តទល់ព្រះរាជអាជ្ញា ICTR-99-50-A សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំបង្កើនចំនួនពាក្យសម្រាប់សារណាឆ្លើយតប” ចុះថ្ងៃទី២៥ ខែមេសាឆ្នាំ២០១២ (បដិសេធសំណើសុំបង្វែរចេញពីគោលការណ៍ណែនាំអនុវត្ត)។

សារទុក្ខទាំងពីរ រួមមាននិយមន័យរបស់បទល្មើស និងទម្រង់នៃការទទួលខុសត្រូវ និងបញ្ហានិតិវិធី និងភស្តុតាង និងការរកឃើញខាងអង្គហេតុ និងការរកឃើញខាងផ្លូវច្បាប់ ទាក់ទងនឹងគោលបំណងរួម និងសហឧក្រិដ្ឋកម្មរួម។

## ខ. កាលបរិច្ឆេទកំណត់សម្រាប់ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា

៣. ស្រដៀងគ្នានេះដែរ សហព្រះរាជអាជ្ញាក៏ខកខានមិនបានគាំទ្រដល់សំណើរបស់ខ្លួនសម្រាប់ការពន្យារពេលសម្រាប់ចម្លើយតបរបស់ខ្លួនឲ្យស្មើនឹងរយៈពេលបណ្តឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្តី។ វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តនៅ អវតក ផ្តល់ពេលវេលាខ្លីជាងសម្រាប់ការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ[7]។ វិធីសាស្ត្រដូចគ្នានេះត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះនេះនៅក្នុងកិច្ចដំណើរការនិតិវិធីនៅក្នុងសំណុំរឿង០០១[8]។ វិធានស្តីពីភស្តុងតាង និងនិតិវិធីនៅតុលាការ ICTR និង ICTY ផ្តល់កាលបរិច្ឆេទកំណត់រយៈពេល៧៥ថ្ងៃសម្រាប់ការដាក់បណ្តឹងសាទុក្ខ ចាប់ពីការដាក់ការជូនដំណឹងនៃបណ្តឹងសាទុក្ខ ដែលជាពេលដូចគ្នានឹងកាលបរិច្ឆេទកំណត់ស្នើសុំដោយក្រុមមេធាវីការពារក្តីនៅទីនេះដែរ នៅមុនការបកប្រែ ដែលតម្រូវឲ្យការឆ្លើយតបត្រូវតែបានដាក់ក្នុងរយៈពេល៤០ថ្ងៃចាប់ពីថ្ងៃដាក់សារណាបណ្តឹងសាទុក្ខ[9]។ នៅក្នុងករណីនេះចម្លើយតបរបស់សហព្រះរាជអាជ្ញាត្រូវតែដាក់កម្រិតដូចគ្នាដែរ។

## គ. ការពន្យារពេលកាលកំណត់នៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ

៤. ជាចុងបញ្ចប់សហព្រះរាជអាជ្ញាមិនបានផ្តល់យុត្តិសាស្ត្រច្បាប់ ឬហេតុផលក្នុងការគាំទ្រទស្សនៈរបស់ខ្លួនដែលថាការពន្យារពេលកាលកំណត់សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខថា "មិនចាំបាច់"នោះទេ។ ប្រសិនបើភាពស្មុគស្មាញចំពោះបញ្ហាបណ្តឹងសាទុក្ខចាំបាច់ដល់ការពន្យារពេលសម្រាប់រយៈពេល

---

[7] សូមមើល វិធាន៧១(២), ៧៧(២), ៧៧ស្ទួន(២),១០៧(១),(៤), មាត្រា៨.៣ នៃសេចក្តីណែនាំអនុវត្តដាក់ឯកសារ។

[8] ករណី០០១/១៨-០៧-២០០៧-SC ឯកសារ F14/3 "សេចក្តីណែនាំលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេល ដើម្បីឆ្លើយតបទៅនឹងសារណាបណ្តឹងសារទុក្ខរបស់ក្រុមមេធាវីការពារក្តីចុះថ្ងៃ៧ ខែធ្នូ ២០១០ (ដោយបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាពេល ៣០ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងសារណាបណ្តឹងសារទុក្ខរបស់ក្រុមមេធាវីការពារក្តី តទល់នឹងកាលពេលវេលាកំណត់៩០ថ្ងៃសម្រាប់សារណារបស់ក្រុមមេធាវីការក្តី)។

[9] សូមមើលវិធានស្តីពីភស្តុតាង និងនិតិវិធី នៅ ICTR និង ICTY វិធាន១១១(ក), ១១២(ក)។

បណ្តឹងសាទុក្ខ និងចំនួនទំព័រសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ នោះការពន្យារពេលលើកាលកំណត់សម្រាប់សេចក្តីជូនដំណឹងគឺចាំបាច់ដូចតែគ្នា ដែលបង្កើតជាដែនកំណត់លើបណ្តឹងរបស់ភគីនីមួយៗ និងអាស្រ័យហេតុនេះហើយសន្មត់ជាមុននូវការវិភាគមួយលើសាលក្រមទាំងមូល និងមូលដ្ឋានសក្តានុពលសម្រាប់បណ្តឹងសាទុក្ខ។ រយៈពេល៦០ថ្ងៃសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលបានស្នើឡើងក្នុងសំណើសុំបង្កើនចំនួនទំព័រ និងសុំពន្យារពេលកំណត់ (នៅមុនការបកប្រែ) គឺសមស្របនឹងការកំណត់នៅក្នុងការអនុវត្តជាអន្តរជាតិ[10]។

៥. មេធាវីការពារក្តីកត់សម្គាល់ថា ពេលវេលាសម្រាប់បកប្រែការជូនដំណឹងដែលស្នើឡើងដោយមេធាវីដែលមានចំនួន៥០ទំព័រ (ដែលសហព្រះរាជអាជ្ញាមិនមានការជំទាស់) គឺវាប្រហាក់ប្រហែលពាក់កណ្តាលនៃរយៈពេល៣០ថ្ងៃសម្រាប់ការដាក់ការជូនដំណឹង ហើយនឹងចាំបាច់ដាក់ជូនទៅអង្គភាពបកប្រែភាសានៅចំ ឬនៅមុនកាលបរិច្ឆេទនៃការឆ្លើយតបនេះ។ ការជូនដំណឹង អាចត្រូវបានដាក់ក្នុងរយៈពេល៦០ថ្ងៃ ជាភាសាអង់គ្លេស ឬជាភាសាបារាំង ដោយភាសាខ្មែរអាចដាក់តាមក្រោយឲ្យបានកាន់តែឆាប់កាន់តែល្អ ដែលនេះជាជម្រើសផ្សេងទៀតក្រៅពីរយៈពេល៧៤ ថ្ងៃសម្រាប់ការដាក់ជូននូវសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលបានស្នើឡើងនៅក្នុងសំណើសុំបង្កើនចំនួនទំព័រ និងសុំពន្យារពេលកំណត់ក្នុងករណីនោះពេលវេលាសម្រាប់សារណាបណ្តឹងសាទុក្ខនឹងចាប់ផ្តើមនៅពេលដែលសេចក្តីជូនដំណឹងត្រូវបានដាក់ជូនតែមួយភាសា ជាជាងថ្ងៃបរិច្ឆេទដែលជូនដំណឹងជាផ្លូវការ អាស្រ័យហេតុនេះហើយនឹងបន្ថយនូវពេលវេលាទាំងអស់បានរយៈពេល១៤ថ្ងៃ។

៦. អាស្រ័យលើហេតុផលទាំងនេះ មេធាវីការពារក្តីសូមស្នើដោយគោរពដល់អង្គជំនុំជម្រះតុលាកំពូលថា៖

a. កម្រិតការឆ្លើយតបរួមរបស់ព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន និង នួន ជា ឲ្យនៅត្រឹមតែមួយភាគបីវែងជាងបណ្តឹងសាទុក្ខរបស់ក្រុមនីមួយៗ។

---

[10] សូមមើល *Prosecutor v. Dordevic*, IT-05-87/I-A "សេចក្តីសម្រេចលើសំណើ Vlastimir Dordevic សម្រាប់ការពន្យារពេលដើម្បីសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ", ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ (ផ្តល់រយៈពេល៩០ថ្ងៃសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ "ដោយពិចារណាថា វាជាផលប្រយោជន៍យុត្តិធម៌ ដើម្បីធានាថា ភាគីទាំងអស់មានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំសេចក្តីជូនដំណឹងដ៏មានអត្ថន័យដោយស្របទាំងស្រុងនឹងច្បាប់ដែលមានជាធរមាន")។

b. កម្រិតពេលវេលាឆ្លើយតបរបស់ព្រះរាជអាជ្ញាទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន និង នួន ជា ឲ្យនៅត្រឹមតែប្រហែលពាក់កណ្ដាលនៃពេលវេលាដែលផ្ដល់ជូនសម្រាប់បណ្ដឹងសាទុក្ខ ចាប់ពីពេលការដាក់ជូននូវសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និង

c. ពន្យារពេលកំណត់នៃការដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ដល់រយៈពេល៦០ថ្ងៃគិតចាប់ពីថ្ងៃដែលចេញសាលក្រម ព្រមទាំងផ្ដល់ពេលវេលាបន្ថែម១៤ថ្ងៃសម្រាប់ការបកប្រែ ឬជាជម្រើសផ្សេងទៀតអនុញ្ញាតឲ្យដាក់ជូនជាមួយភាសាសិន។

**សហមេធាវីការពារក្ដី នួន ជា និង ខៀវ សំផន**

សុន អារុណ | Victor KOPPE

KONG Sam Onn | Anta GUISSÉ | Arthur VERCKEN